## ខ្លឹមសារសង្ខេបនៃការសិក្សាស្រាវជ្រាវរបស់អង្គការនារីដើម្បីសន្តិភាព

# សំឡេងក្មេងស្រីជនជាតិភាគតិច

ខែមេសា ឆ្នាំ២០២២



## អ្វីដែលអ្នកគួរដឹង

ប្រទេសកម្ពុជាជាប្រទេសមួយដែលមានភាពចម្រុះ បើទោះបីជាប្រជាជនសរុប ៩០ ភាគរយជាជនជាតិខ្មែរ និងកាន់ព្រះពុទ្ធសាសនាក៏ដោយ ក៏មានប្រជាជនប្រហែលជា១០ភាគរយទៀតមកពីក្រុមដែលមានសាសនា ជាតិសាសន៍ និងវប្បធម៌ផ្សេងគ្នាផងដែរ។ នៅក្នុងសង្គមមួយដែលស្ត្រីទូទៅបន្តប្រឈមនឹងការរើសអើងនិងភាពងាយរងគ្រោះ ក្រុមស្ត្រីមកពីសហគមន៍ជនជាតិភាគតិចកាន់តែទទួលរងនូវ "បន្ទុកផ្ទួនៗ"។ ភាពប្រទាក់ក្រឡាគ្នានៃយេនឌ័រ អាយុ និង ជនជាតិភាគតិច គឺមិនត្រូវបានពិនិត្យមើលអោយស៊ីជម្រៅនៅឡើយនៅកម្ពុជា។ ជាក់ស្តែង វិសមភាពយេនឌ័រ និងការរើសអើងលើជនជាតិភាគតិច គឺជាបញ្ហាដ៏រសើបដែលកើតមានឡើង។ ជាលទ្ធផល ក្មេងស្រីជនជាតិភាគតិចនៅក្នុងប្រទេសកម្ពុជា តែងតែជាក្រុមដែលងាយរងគ្រោះ ផាត់ចេញ និងគ្មានឱកាសចូលរួមក្នុងការបញ្ចេញមតិរបស់ខ្លួនទៅកាន់ថ្នាក់ជាតិនោះទេ។ គួបផ្សំនឹងកង្វះទិន្នន័យ ឬការវិភាគនានាទៅលើក្រុមជនជាតិភាគតិច បញ្ហាក្មេងស្រីជនជាតិភាគតិចទាំងនោះមិនត្រូវបានគេមើលឃើញ និងរាប់បញ្ចូលក្នុងការពិភាក្សានៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិនោះឡើយ។ ជាលទ្ធផល គេមើលឃើញថា ការអន្តរាគមន៍ជាលក្ខណៈជំនួយអភិវឌ្ឍន៍ទៅលើបញ្ហាក្មេងស្រីជនជាតិភាគតិចមិនសូវមាន ឬ មានតិចតួចណាស់។

### តើការសិក្សាស្រាវជ្រាវនេះនិយាយអំពីអ្វី ?

ការសិក្សាស្រាវជ្រាវ ដែលមានឈ្មោះថា "សំឡេងក្មេងស្រីជនជាតិភាគតិច" គឺជាលទ្ធផលនៃការស្រាវជ្រាវអស់រយៈពេលជិត ៣ ឆ្នាំ ដែលមានការចូលរួមយ៉ាងសកម្មពីក្មេងស្រីមកពីសហគមន៍ចម្រុះជាតិសាសន៍ សាសនា និងវប្បធម៌ នៅក្នុងប្រទេសកម្ពុជា។ វាជាការរួមចំណែកមួយយ៉ាងសំខាន់ក្នុងការផ្តល់នូវចំណេះដឹងថ្មីមួយ ពីភាពប្រទាក់ក្រឡាគ្នារវាង យេនឌ័រ អាយុ និង អត្តសញ្ញាណ។ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងដោយផ្តោតសំខាន់ទៅលើបទពិសោធន៏ជាក់ស្តែងក្នុងការរស់នៅ ទស្សនៈវិស័យ បញ្ហាប្រឈម ក្តីសង្ឃឹម និងក្តីស្រម៉ៃសម្រាប់ក្មេងស្រីដែលបានចូលរួមចំនួន ៣៤៣ នាក់ កន្លងមកពីសហគមន៍ជនជាតិភាគតិចទាំងបួននៅប្រទេសកម្ពុជា ដូចជា ជនជាតិដើមភាគតិច ជនជាតិភាគតិចវៀតណាម ជនជាតិចាមមូស្លីម និង ខ្មែរក្រោម។

### តើការស្រាវជ្រាវនេះត្រូវបានធ្វើឡើងដោយរបៀបណា ?

ការសិក្សាស្រាវស្រាវជ្រាវនេះ គឺជាការចូលរួមចំណែកទាំងស្រុងដោយមានការដឹកនាំផ្ទាល់ពីសហគមន៏។ ដោយបានប្រើវិធីសាស្រ្តចម្រុះការសិក្សស្រាវស្រាវជ្រាវនេះចាប់ផ្តើមជាមួយនឹងវិធីសាស្រ្តស្រាវជ្រាវបែបគុណវិស័យ ដោយផ្តោតសំខាន់ទៅលើសាច់រឿង និងការចែករំលែកព័ត៌មាន តាមរយៈការស្រាវជ្រាវបែបសន្ទនា “Facilitative Listening Design (FLD)”។ ការស្រាវជ្រាវបែបសន្ទនានេះ ជាវិធីសាស្រ្តប្រមូលទិន្នន័យមួយ ដែលប្រើប្រាស់ការស្តាប់ និងការសន្ទនាជាមធ្យោបាយចម្បងក្នុងការស្វែងយល់ពីមតិយោបល់បុគ្គល ដោយប្រើប្រាស់ឧបករណ៍មានលក្ខណៈបត់បែនក្នុងការប្រមូលទិន្នន័យ។ របកគំហើញបឋមនៃការសិក្សាស្រាវជ្រាវបែបសន្ទនានេះ បានក្លាយជាមូលដ្ឋានគ្រឹះក្នុងការបង្កើតសំណួរសម្រាប់ការស្ទង់មតិ ដែលប្រើដើម្បីប្រមូលទិន្នន័យបែបបរិមាណ អំពីក្មេងស្រីជនជាតិភាគតិច។ ការពិភាក្សាជាក្រុមត្រូវបានធ្វើឡើងដំណាលគ្នា ដើម្បីឲ្យសមាជិកសហគមន៏ដទៃទៀត បានចែករំលែកមតិនិងទស្សនៈរបស់ពួកគេអំពីស្ថានភាព កម្រិតនៃការចូលរួម និង ឱកាសរបស់ក្មេងស្រីនៅក្នុងសហគមន៏របស់ពួកគេ។

## តើអ្វីដែលយើងបានរកឃើញ ?

ជីវិតរបស់ក្មេងស្រីជនជាតិភាគតិចក្នុងប្រទេសកម្ពុជា មានភាពខុសគ្នាទៅតាមក្រុមជនជាតិនីមួយៗ។ សម្រាប់ក្មេងស្រីជនជាតិដើមភាគតិច ភាសានិងវប្បធម៌ប្រពៃណីមានសារៈសំខាន់យ៉ាងជ្រាលជ្រៅចំពោះពួកគេ ប៉ុន្តែវាក៏ឧបសគ្គផងដែរ មិនត្រឹមតែនៅក្នុងសង្គមខ្មែរទូទៅប៉ុណ្ណោះទេ សូម្បីតែនៅក្នុងសហគមន៍របស់ពួកគេ។ បទដ្ឋានសង្គម និងផ្នត់គំនិតអវិជ្ជមានទៅលើក្មេងស្រី ជារឿយៗបានកម្រិតឱកាសមិនអោយក្មេងស្រីសម្រេចនូវក្តីស្រម៉ៃរបស់ពួកគេ។ លើសពីនេះ ក្មេងស្រីជនជាតិភាគតិចវៀតណាមក៏កំពុងប្រឈមនឹងបញ្ហាជាច្រើនដូចជា បញ្ហាអត្តសញ្ញាណផ្លូវច្បាប់ អសន្តិសុខលំនៅដ្ឋាន និងការរើសអើងផ្សេងៗ។ ពួកគេជារឿយៗនៅដាច់ដោយឡែកពីអ្នកដទៃ និងកង្វះការទទួលបាននូវសេវាមូលដ្ឋាន ដូចជាការអប់រំជាដើម។ ចំណែកឯក្មេងស្រីជនជាតិចាមមូស្លីមវិញ ពួកគេបានបង្ហាញការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើអត្តសញ្ញាណ ភាសា និងសាសនារបស់ពួកគេ។ ប៉ុន្តែជាជារឿយៗ ពួកគេត្រូវបានរងគំនាបឲ្យបោះបង់ការសិក្សា ដើម្បីធ្វើការជួយផ្គត់ផ្គង់ជីវភាពគ្រួសារ។ ក្មេងស្រីខ្មែរក្រោម ជាទូទៅប្រឈមមុខជាមួយ បទដ្ឋានសង្គម ទាក់ទងទៅនឹងតួនាទីយេនឌ័រនៅក្នុងសហគមន៍ ទំនួលខុសត្រូវលើការងារផ្ទះ ហើយពួកគេមានអារម្មណ៏ថា មានសិទ្ធិតិចតួចបំផុតក្នុងការគ្រប់គ្រងលើការសម្រេចចិត្តរបស់ខ្លួនឯង។

បើទោះបីជាបរិបទរបស់ក្មេងស្រីមកពីក្រុមនីមួយៗមានភាពខុសប្លែកគ្នាក៏ដោយក៏មានចំណុចដូចគ្នាមួយចំនួនដែលត្រូវបានរកឃើញ ក្នុងចំណោមក្មេងស្រីជនជាតិភាគតិច ទាំងនោះផងដែរ។ តាមការសិក្សាស្រាវជ្រាវបានបញ្ជាក់ថា មានបញ្ហារួមមួយចំនួនដែលក្រុមជនជាតិភាគតិចទាំងអស់បានជួបប្រទះក្នុងសហគមន៍របស់ពួកគេ។

### ភាពក្រីក្រ

ក្មេងស្រីជនជាតិភាគតិចស្ទើរតែទាំងអស់ មើលឃើញថាពួកគេកំពុងរស់នៅក្នុងស្ថានភាពក្រីក្រជាងក្មេងស្រីជនជាតិខ្មែរទូទៅ។

### កង្វះការអប់រំផ្លូវភេទ និងការទទួលបានសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ

ក្មេងស្រីជនជាតិភាគតិចមានអារម្មណ៏ថា ពួកគេឆ្លងកាត់ភាពពេញវ័យដោយមិនបានយល់ដឹងច្បាស់ពីការលូតលាស់រាងកាយរបស់ខ្លួន ហើយអាចជជែកពីបញ្ហារបស់ខ្លួនបានតែជាមួយសមាជិកគ្រួសារដែលជាស្ត្រី ឬមិត្តភក្តិជិតស្និតតែប៉ុណ្ណោះ។ ដោយរស់នៅក្នុងសហគមន៏ដាច់ស្រយាល ក្មេងស្រីជនជាតិភាគតិចបានចែករំលែកការយល់ឃើញដូចៗគ្នាថា ពួកគេមានភាពខ្វះខាត ក្នុងការទទួលបានព័ត៌មានទាក់ទងនឹងការអប់រំផ្លូវភេទ ការទទួលបានសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ។

### តួនាទីយេនឌ័រ និងការរំពឹងទុកទៅលើក្មេងស្រី

ក្មេងស្រីមកពីសហគមន៏ជនជាតិភាគតិចមានអារម្មណ៍ថាមិនមានទំនុកចិត្ត ក្នុងការជជែកជាសាធារណ:ទាំងក្នុងសហគមន៏របស់ពួកគេ និងក្នុងក្រុមជនជាតិភាគច្រើនដទៃទៀត។ ពួគគេមានអារម្មណ៏ថា សំឡេងរបស់ពួកគេមិនត្រូវបានគេស្តាប់ និងផ្តល់តម្លៃនោះទេក្នុងសហគមន៍របស់ពួកគេ។

### មោទនភាពទៅលើអត្តសញ្ញាណ

ទោះបីជាមានអារម្មណ៏ថា មិនត្រូវបានផ្តល់តម្លៃក៏ដោយក៏ក្មេងស្រីជនជាតិភាគតិចទាំងនោះតែងតែមានមោទនភាពចំពោះ អត្តសញ្ញាណ សាសនា និងវប្បធម៌ផ្ទាល់ខ្លួន ជាជនជាតិភាគតិច។ ពួកគេមានមោទនភាពក្នុងការនិយាយភាសាដើមកំណើតក្រៅពីភាសាខ្មែរ និង ការបង្ហាញពីប្រពៃណីផ្សេងៗគ្នារបស់ពួកគេ។

### បទពិសោធន៍ទទួលរងការរើសអើងពីអ្នកដទៃ

ក្មេងស្រីជនជាតិភាគតិចស្ទើរតែទាំងអស់ប្រឈមនឹងការរើសអើង។ ជារឿយៗពួកគេត្រូវបានសើចចំអកដោយសារតែប្រពៃណី និងទំនៀមទម្លាប់របស់ពួកគេ ឬ ដោយសារតែការនិយាយភាសាខ្មែរមិនច្បាស់ ហើយមានអារម្មណ៍ថា "ខ្លួនជាអ្នកដទៃ" នៅក្នុងសង្គមកម្ពុជា។

### ការបោះបង់ការសិក្សា និងកង្វះឱកាសទទួលបានការអប់រំខ្ពស់

ការទទួលបានការអប់រំនៅក្នុងសាលា ជារឿងមួយដ៏ពិបាកសម្រាប់ក្មេងស្រីជនជាតិភាគតិច។ ភាគច្រើនពួកគេបោះបង់ការសិក្សានៅកម្រិតវិទ្យាល័យ ដោយសារមូលហេតុមួយចំនួនដូចជា៖ ការរៀបការ ធ្វើការ ឬ ការមិនមានឯកសារគ្រប់គ្រាន់សម្រាប់ការសិក្សានៅសាលារដ្ឋជាដើម។ ហើយសម្រាប់អ្នកដែលមានបំណងចង់ចូលរៀននៅសកលវិទ្យាល័យ ឬ បន្តការសិក្សាថ្នាក់ឧត្តមសិក្សា តែងមានឧបសគ្គជាច្រើនដែលរារាំងពួកគេដូចជា៖ ការចំណាយផ្សេងៗ ទំនួលខុសត្រូវលើការងារផ្ទះ ផ្នត់គំនិតយេនឌ័រនៅក្នុងសហគមន៏របស់ពួកគេ ការធ្វើដំណើរឆ្ងាយ ទំនួលខុសត្រូវលើការងារផ្សេងៗ និងការរើសអើង ដែលសុទ្ធតែជាតែជាកត្តាសំខាន់ ដែលរារាំងក្មេងស្រីជនជាតិភាគតិច ក្នុងការទទួលបានការអប់រំរបស់ពួកគេ។

## តើអ្នកដឹកនាំការស្រាវជ្រាវជានរណា ?

គំនិតផ្តួចផ្តើមនៃការស្រាវជ្រាវនេះត្រូវបានដឹកនាំដោយក្មេងស្រីជនជាតិភាគតិច និងស្ត្រីវ័យក្មេងពីសហគមន៍ទាំងបួន ក្រោមការដឹកនាំគម្រោងដោយ កញ្ញា សេន លេ នៃអង្គការនារីដើម្បីសន្តិភាព ដោយមានការឧបត្ថម្ភគាំទ្រពី អង្គការ Danmission និងសហការគាំទ្រពីកម្មវិធីវ៉យនៃអង្គការអ៊ុកស្វាម និង Pangea Giving។

## តើអ្នកអាចប្រើប្រាស់ការស្រាវជ្រាវនេះដោយរបៀបណា ?

ការស្រាវជ្រាវនេះអាចូលរួមចំណែកក្នុងគោលនយោបាយ និងការអនុវត្តពាក់ព័ន្ធមួយចំនួន។ នៅថ្នាក់ជាតិ ក្មេងស្រីជនជាតិភាគតិចត្រូវតែទទួលបានការគិតគូរក្នុងផ្នែកនានា ជាពិសេសទាក់ទងនឹងសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ពួកគេ។ ភាពប្រទាក់ក្រឡាទាំងអស់នេះ អាចផ្តល់ការយល់ដឹងកាន់តែស៊ីជម្រៅអំពីស្រទាប់នីមួយៗនៃអត្តសញ្ញាណដែលអាចជះឥទ្ធិពលដល់ការជីវិតរបស់ក្មេងស្រី។ បន្ទុកផ្ទួនៗរបស់ក្មេងស្រីជនជាតិភាគតិច ចាំបាច់ត្រូវពិចារណាឡើងវិញដោយគិតគូពី អាយុ យេនឌ័រ និងអត្តសញ្ញាណជាក្រុមភាគតិចរបស់ពួកគេ។ ក្រសួងពាក់ព័ន្ធត្រូវតែដាក់បញ្ចូលនូវការគិតគូពីភាពប្រទាក់ក្រឡាទាំងនោះអោយបានស៊ីជម្រៅ ទៅក្នុងការបង្កើតគោលនយោបាយផ្សេងៗ និងធានាថាក្មេងស្រីជនជាតិភាគតិចត្រូវបានដាក់បញ្ចូលយ៉ាងយកចិត្តទុកដាក់ ជាពិសេសក្នុងការសម្រេចបាននូវគោលដៅថ្នាក់ជាតិ ក្នុងការ អភិវឌ្ឍន៏ប្រទេស។ ដៃគូអភិវឌ្ឍន៏ ដែលធ្វើការនៅក្នុងប្រទេសកម្ពុជាក៏ត្រូវតែគិតគូរដល់ក្មេងស្រីជនជាតិភាគតិចផងដែរ ជាពិសេស នៅក្នុងគំនិតផ្តួចផ្តើមនានាទាក់ទងនឹងវិស័យយេនឌ័រ ដែលជារឿយៗមិនបានរាប់បញ្ចូលជនជាតិភាគតិច។ ការតស៊ូមតិរបស់អង្គការសង្គមស៊ីវិល ត្រូវតែបង្កើន អោយកាន់តែទូលំទូលាយ ដើម្បីជំរុញអោយមានការយល់ដឹងអំពីបញ្ហាដែលក្មេងស្រីជនជាតិភាគតិចបានជួបប្រទះ ទៅដល់សាធារណ:ជនអោយបានយល់កាន់តែច្បាស់។ វាមិនត្រឹមតែជាការលើកកម្ពស់នូវការរាប់បញ្ចូលពួកគេប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការដាក់អាទិភាពអោយពួកគេនៅក្នុងកិច្ចខំប្រឹងប្រែងនានា ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៏ប្រកបដោយចីរភាពនិងការដាក់អាទិភាពអោយពួកគេមានសំឡេងក្នុងគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងសិទ្ធិមនុស្សដែលផ្តោតទៅលើជនជាតិភាគតិចងាយរងគ្រោះបំផុត។

សម្រាប់ព័ត៌មានបន្ថែមពីការសិក្សាស្រាវជ្រាវនេះ សូមអានរបាយការណ៍ស្រាវជ្រាវនេះពិស្តារក្នុងគេហទំព័ររបស់អង្គការនារីដើម្បីសន្តិភាព **www.wpmcambodia.org** ឬ ទំនាក់ទំនងមកការិយាល័យយើងខ្ញុំផ្ទាល់ ដើម្បីស្នើសុំសៀវភៅស្រាវជ្រាវនេះ។

Empower women and youth
Transform conflict and build peace

